រដ្ឋកម្ពុជា

ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល

# ច្បាប់
## ស្តីពី
## ការបង្កើតពន្ធប្រថាប់ត្រា

មាត្រា ១.- ត្រូវបានបង្កើតពន្ធប្រថាប់ត្រា ។

មាត្រា ២.- ពន្ធប្រថាប់ត្រាត្រូវអនុវត្តលើការផ្ទេរកម្មសិទ្ធិតាមរូបភាព លក់ ទិញ :

- ផ្ទះ និង ដីសង់លំនៅដ្ឋាន ៦ ភាគរយ
- រថយន្តគ្រប់ប្រភេទ ៤ ភាគរយ
- ម៉ូតូគ្រប់ប្រភេទ ២ ភាគរយ
- ទូក កាណូត កប៉ាល់ សាឡាង ២ ភាគរយ

មាត្រា ៣.- ចំណូលដែលបានមកពីពន្ធប្រថាប់ត្រា ត្រូវបង់ចូលថវិការដ្ឋ ។

មាត្រា ៤.- តំណាង ឬ ភ្នាក់ងាររាជ្យដ្ឋានណា ដែលបង្ខំទារ ឬ ទទួលយកប្រាក់ពន្ធប្រថាប់ត្រាដែលគ្មានចែងក្នុងច្បាប់ ឬ ដែលលើសពីការកំណត់ក្នុងច្បាប់ ត្រូវផ្តន្ទាទោស :

១- ដាក់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ បើកំរៃដែលបានមកពីអំពើល្មើស មានចំនួនតិចជាង ១០.០០០រ " មួយម៉ឺនរៀល " ។

២- ដាក់ពន្ធនាគារពី ៥ ឆ្នាំ ដល់ ១០ ឆ្នាំ បើកំរៃដែលបានមកពីអំពើល្មើសមានចំនួន ពី ១០.០០០រ " មួយម៉ឺនរៀល" ដល់ ១០០.០០០រ " មួយសែនរៀល"

៣- ដាក់ពន្ធនាគារ ពី ១០ ឆ្នាំឡើងទៅ រហូតដល់អស់មួយជីវិត បើកំរៃដែលបានមកពីអំពើល្មើស មានចំនួនលើសពី ១០០.០០០រ " មួយសែនរៀល " ឡើងទៅ ។

មាត្រា ៥.- បែបបទនៃការប្រថាប់ត្រា និង បែបបទនៃការប្រមូលពន្ធប្រថាប់ត្រា ត្រូវកំណត់ដោយអនុក្រឹត្យ ។

ច្បាប់នេះ រដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត នៅថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ១៩៩១ នាសម័យប្រជុំលើកទី ២០ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩១

ជ. រដ្ឋសភា

ប្រធាន

ហត្ថលេខា និង ត្រា : ជា ស៊ីម

ថតចំលងត្រឹមត្រូវតាមច្បាប់ដើម

អគ្គលេខាធិការនៃក្រុមប្រឹក្សារដ្ឋ

ចាន់ វ៉េន